ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# គោលការណ៍ណែនាំ
# ស្ដីពី
# ការវាយតម្លៃ ការជ្រើសរើស និង
# ការផ្ដល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ

រៀបចំដោយ

នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ

ឧសភា ២០២៤

## បុព្វកថា

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ចក្ខុវិស័យ ក្នុងការប្រែក្លាយកម្ពុជាជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងចំណូលខ្ពស់ក្នុងឆ្នាំ២០៥០។ ដើម្បីសម្រេចចក្ខុវិស័យនេះ អនុវិស័យឧត្តមសិក្សា ដើរតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្សឱ្យមានសមត្ថភាពខ្ពស់ស្របតាមទីផ្សារការងារ និងជំរុញការស្រាវជ្រាវ និងនវានុវត្តន៍ដែលផ្សារភ្ជាប់នឹងទីផ្សារ និងឆ្លើយតបទៅនឹងការអភិវឌ្ឍជាតិ។

ដើម្បីពង្រឹងគុណភាពបណ្តុះបណ្តាល និងការស្រាវជ្រាវនៅឧត្តមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ រួមមានយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ គោលនយោបាយអភិវឌ្ឍឧស្សាហកម្ម ២០១៥-២០២៥ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជា ឆ្នាំ២០៣០ គោលនយោបាយស្តីពីចក្ខុវិស័យឧត្តមសិក្សាឆ្នាំ២០៣០ ផែនទីបង្ហាញផ្លូវឧត្តមសិក្សាកម្ពុជាឆ្នាំ២០៣០ និងក្រោយ២០៣០ និងយុទ្ធសាស្ត្រអនុវិស័យឧត្តមសិក្សា ២០២១-២០៣០។ សមិទ្ធផលគួរឱ្យកត់សម្គាល់ រួមមានការបង្កើនបរិមាណនិស្សិតចូលរៀននៅឧត្តមសិក្សាទាំងកម្រិតបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ជាពិសេសជំនាញស្ទែម ការបង្កើនគុណវុឌ្ឍិបុគ្គលិកអប់រំ ការអភិវឌ្ឍសមត្ថភាពស្ថាប័ន ការពង្រឹងអេកូស៊ីស្ទែមសម្រាប់ការស្រាវជ្រាវ ការរៀបចំ ឬកែលម្អកម្មវិធីសិក្សាឱ្យមានស្តង់ដាជាតិ និងអន្តរជាតិ និងការសាងសង់ ជួសជុលអគារសិក្សា និងមន្ទីរពិសោធន៍ដោយបំពាក់បរិក្ខារ និងឧបករណ៍ទំនើប នៅតាមគ្រឹះស្ថានឧត្តមសិក្សា ដើម្បីបម្រើដល់ការបង្រៀននិងការរៀន និងការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា។

ដើម្បីធានានិរន្តរភាព និងរួមចំណែកអភិវឌ្ឍធនធានមនុស្សនៅតាមគ្រឹះស្ថានឧត្តមសិក្សាឱ្យមានគុណភាពខ្ពស់ កម្ពុជាពិតជាត្រូវការចាំបាច់នូវការលើកកម្ពស់ស្នាដៃសិក្សា និងស្រាវជ្រាវរបស់បុគ្គលិកអប់រំ និងគ្រូបង្រៀនគ្រប់វិស័យ។ ក្នុងបរិការណ៍នេះ ក្រសួង បាននិងកំពុងអនុវត្តការជ្រើសរើស និងផ្តល់ឋានៈសាស្ត្រាចារ្យ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យជំនួយ ក្នុងវិស័យអប់រំ ដើម្បីលើកកម្ពស់គុណវុឌ្ឍិ និងលើកទឹកចិត្តបុគ្គលិកអប់រំ និងគ្រូបង្រៀននៅឧត្តមសិក្សា។

ដើម្បីពង្រឹងការជ្រើសរើស និងការផ្តល់ឋានៈសាស្ត្រាចារ្យ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យជំនួយក្នុងវិស័យអប់រំ ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ក្រសួង បានរៀបចំគោលការណ៍ណែនាំស្តីពី «ការវាយតម្លៃ ការជ្រើសរើស និងការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ» ដោយយោងលើព្រះរាជក្រឹត្យ នស/រកត/០១១៣/០៩២ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យ និងប្រកាសលេខ ១៤៨៧ អយក.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ ស្តីពីការជ្រើសរើស និងផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ។ គោលការណ៍ណែនាំនេះ បង្ហាញលម្អិតអំពី លក្ខណៈវិនិច្ឆ័យសម្រាប់ឋានៈសាស្ត្រាចារ្យកម្រិតនីមួយៗ របៀបវាស់វែង និងនីតិវិធីស្នើសុំ និងផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ។

ក្នុងនាមក្រសួងអប់រំ យុវជន និងកីឡា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគណៈកម្មការត្រួតពិនិត្យ និងផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ ជាពិសេសនាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ ដែលជាលេខាធិការដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានរៀបចំគោលការណ៍ណែនាំស្តីពី «ការវាយតម្លៃ

ការជ្រើសរើស និងការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ»នេះ ដើម្បីសម្រួលដល់ការវាយតម្លៃជ្រើសរើស និងផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា គ្រឹះស្ថានឧត្តមសិក្សានឹងយកចិត្តទុកដាក់អនុវត្តគោលការណ៍ណែនាំនេះ ដោយស្មារតីទទួលខុសត្រូវខ្ពស់ សម្រាប់ការរៀបចំដាក់ស្នើសុំឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ។ ខ្ញុំក៏សូមលើកទឹកចិត្តឱ្យគ្រឹះស្ថានឧត្តមសិក្សាផ្សព្វផ្សាយគោលការណ៍ណែនាំនេះ ឱ្យបានទូលំទូលាយដល់បុគ្គលិកអប់រំ និងគ្រូបង្រៀន ដែលមានបំណងដាក់ពាក្យស្នើសុំឋានៈសាស្ត្រាចារ្យក្នុងកម្រិតណាមួយ ដើម្បីជានាដំណើរការនៃការវាយតម្លៃ ការជ្រើសរើស និងការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំនេះប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ដើម្បីរួមចំណែកអភិវឌ្ឍអនុវិស័យឧត្តមសិក្សា និងសង្គមសេដ្ឋកិច្ចជាតិកម្ពុជាទាំងមូល។

ថ្ងៃព្រហស្បតិ៍ ២កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# មាតិកា


បុព្វកថា.....i

មាតិកា.....iii

១. សេចក្តីផ្តើម.....១

២. និទ្ទេសបទ និងការដាក់ពិន្ទុ.....១

៣. លក្ខណៈវិនិច្ឆ័យលើការវាយតម្លៃ ជ្រើសរើស និងផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ.....២

៣.១. លក្ខណៈវិនិច្ឆ័យបឋមដើម្បីមានសិទ្ធិគ្រប់គ្រាន់ក្នុងការដាក់ពាក្យស្នើសុំឋានៈសាស្ត្រាចារ្យ.....២

៣.២. លក្ខណៈវិនិច្ឆ័យសម្រាប់កម្រិតសញ្ញាបត្រ.....២

៣.៣. លក្ខណៈវិនិច្ឆ័យសម្រាប់ស្នាដៃបោះពុម្ពអត្ថបទស្រាវជ្រាវ.....២

៣.៤. លក្ខណៈវិនិច្ឆ័យសម្រាប់ស្នាដៃបោះពុម្ពសៀវភៅសិក្សា.....៤

៣.៥. លក្ខណៈវិនិច្ឆ័យសម្រាប់បទពិសោធបង្រៀន ឬបទពិសោធធ្វើបទបង្ហាញជាវាគ្មិនក្នុងសន្និសីទ ឬវេទិកាសាធារណៈ.....៥

៣.៦. លក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់ស្នាដៃបង្រៀន ឬការដឹកនាំនិស្សិត.....៥

៣.៧. លក្ខណៈវិនិច្ឆ័យសម្រាប់ស្នាដៃផ្សេងៗ.....៦

៣.៨. លក្ខណៈវិនិច្ឆ័យសម្រាប់ក្រមសីលធម៌វិជ្ជាជីវៈ.....៦

៣.៩. លក្ខណៈវិនិច្ឆ័យសម្រាប់ការយកលក្ខខណ្ឌមួយជំនួសឱ្យលក្ខខណ្ឌមួយទៀត.....៧

៤. ការបូកពិន្ទុបន្ថែមលើស្នាដៃបោះពុម្ពអត្ថបទស្រាវជ្រាវ ឬសៀវភៅសិក្សា.....៧

៤.១. ការលើកទឹកចិត្តដល់ការបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវ.....៧

៤.២. ការលើកទឹកចិត្តដល់ការបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវដែលមានគុណភាពខ្ពស់.....៧

៤.៣. ការលើកទឹកចិត្តដល់ការបោះពុម្ពផ្សាយសៀវភៅសិក្សា.....៨

៤.៤. ការលើកទឹកចិត្តដល់ការបោះពុម្ពផ្សាយសៀវភៅសិក្សាដែលមានគុណភាពខ្ពស់.....៨

៤.៥. ការលើកទឹកចិត្តដល់ការបោះពុម្ពផ្សាយសៀវភៅ ឬរបាយការណ៍ស្រាវជ្រាវកម្រិតអន្តរជាតិ.....៩

៥. បែបបទ និងនីតិវិធីនៃការអនុវត្តការស្នើសុំឋានៈសាស្ត្រាចារ្យ.....៩

៥.១. នីតិវិធីនៃការដាក់ស្នើសុំឋានៈសាស្ត្រាចារ្យ.....៩

៥.២. ការបញ្ជូនលទ្ធផលនៃការវាយតម្លៃការស្នើសុំឋានៈសាស្ត្រាចារ្យ.....១០

៥.៣. ការរៀបចំឯកសារគាំទ្រការស្នើសុំឋានៈសាស្ត្រាចារ្យ ........ ១០
៥.៤. ការដាក់ស្នើសុំឋានៈសាស្ត្រាចារ្យសាជាថ្មី ........ ១១
៦. ឯកសារដែលបេក្ខជនត្រូវរៀបចំ ដើម្បីស្នើសុំឋានៈសាស្ត្រាចារ្យ ........ ១១
៦.១. ឯកសារដែលបេក្ខជនត្រូវរៀបចំ ដើម្បីស្នើសុំឋានៈសាស្ត្រាចារ្យ ........ ១១
៦.២. ឯកសារគាំទ្រសម្រាប់ការស្នើសុំឋានៈសាស្ត្រាចារ្យ ........ ១២
៧. ការពិនិត្យ និងវាយតម្លៃឋានៈសាស្ត្រាចារ្យដោយគណៈកម្មការត្រួតពិនិត្យ និងផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ ........ ១៥
៨. ឧបសម្ព័ន្ធ ........ ១៧
៨.១. ឧបសម្ព័ន្ធទី១៖ តារាងនិទ្ទេសបទ និងពិន្ទុសម្រាប់ការវាយតម្លៃឋានៈសាស្ត្រាចារ្យ ........ ១៨
៨.២. ឧបសម្ព័ន្ធទី២៖ ពាក្យស្នើសុំឋានៈសាស្ត្រាចារ្យ ........ ២៦
៨.៣. ឧបសម្ព័ន្ធទី៣៖ ជីវប្រវត្តិសង្ខេប ........ ២៨
៨.៤. ឧបសម្ព័ន្ធទី៤៖ លិខិតបញ្ជាក់ពីការបំពេញលក្ខណៈវិនិច្ឆ័យបឋម ........ ៣៣
៨.៥. ឧបសម្ព័ន្ធទី៥៖ លិខិតបញ្ជាក់ពីការបំពេញគ្រប់ពិន្ទុ ដើម្បីទទួលបានឋានៈសាស្ត្រាចារ្យដែលបានស្នើសុំ ........ ៣៤
៨.៦. ឧបសម្ព័ន្ធទី៦៖ ការរៀបចំឯកសារគាំទ្រ ឬភ័ស្តុតាងផ្សេងៗតាមប្រភេទនៃឯកសារ និងតាមលំដាប់លំដោយនៃលក្ខណៈវិនិច្ឆ័យនីមួយៗ ........ ៣៦

## ១. សេចក្ដីផ្ដើម

គោលការណ៍ណែនាំស្ដីពី «ការវាយតម្លៃ ការជ្រើសរើស និងការផ្ដល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ» នេះរៀបចំឡើង ដោយយោងលើព្រះរាជក្រឹត្យ នស/រកត/០១១៣/០៩២ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្ដីពីការផ្ដល់ឋានៈសាស្ត្រាចារ្យ និងប្រកាសលេខ ១៤៨៧ អយក.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ ស្ដីពីការជ្រើសរើស និងផ្ដល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ ក្នុងគោលបំណងបង្ហាញពី (១) របៀបវាយតម្លៃលើលក្ខណៈវិនិច្ឆ័យនីមួយៗ និងភស្ដុតាងដែលបេក្ខជនត្រូវភ្ជាប់សម្រាប់ការដាក់ស្នើសុំឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ (២) បែបបទ និងនីតិវិធី នៃការដាក់ស្នើសុំឋានៈសាស្ត្រាចារ្យ និង (៣) ការពិនិត្យ និងវាយតម្លៃឋានៈសាស្ត្រាចារ្យ ដោយគណៈកម្មការត្រួតពិនិត្យ និងផ្ដល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ ដើម្បីសម្រួលដល់ការអនុវត្តនៃការវាយតម្លៃ ជ្រើសរើស និងផ្ដល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ ឱ្យមានភាពងាយស្រួល តម្លាភាព និងប្រសិទ្ធភាព។

## ២. និទ្ទេសបទ និងការដាក់ពិន្ទុ

លក្ខណៈវិនិច្ឆ័យលើការវាយតម្លៃ ជ្រើសរើស និងផ្ដល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ ត្រូវបានរៀបចំឡើងក្នុងទម្រង់ជានិទ្ទេសបទ (Rubrics) ដោយមានការដាក់ពិន្ទុ និងផ្ដោតលើសូចនាករចម្បងៗ ចំនួន ៤ ដូចខាងក្រោម៖

### ក. ការស្រាវជ្រាវ និងការបោះពុម្ពផ្សាយ (៤០ពិន្ទុ)

- ស្នាដៃបោះពុម្ពអត្ថបទស្រាវជ្រាវ (២០ពិន្ទុ)
- ស្នាដៃបោះពុម្ពសៀវភៅសិក្សា (២០ពិន្ទុ)

### ខ. ការបង្រៀន ឬការធ្វើបទបង្ហាញ និងការទទួលស្គាល់ស្នាដៃបង្រៀន ឬការដឹកនាំនិស្សិត (៣០ពិន្ទុ)

- បទពិសោធបង្រៀន ឬការធ្វើបទបង្ហាញក្នុងសន្និសីទ/វេទិកាសាធារណៈ (១៥ពិន្ទុ)
- ការទទួលស្គាល់ស្នាដៃបង្រៀន ឬការដឹកនាំនិស្សិត (១៥ពិន្ទុ)

### គ. ស្នាដៃផ្សេងៗ (១៥ពិន្ទុ)

- ផលិតផលគំរូ (Prototype) ផលិតផលស្រាវជ្រាវ (Research Product) ប៉ាតង់/ប្រកាសនីយបត្រតក្កកម្ម (Patent) ការបង្កើតកម្មវិធី/សូហ្វវែរ (Applications/Software) ការបង្កើតទ្រឹស្ដី ឬម៉ូដែលក្នុងជំនាញរបស់ខ្លួន ការចូលរួមរៀបចំគោលនយោបាយ ការរៀបចំកម្មវិធីសិក្សា ការបង្កើតវីដេអូបង្រៀន ការពិសោធ ការស្រាវជ្រាវ ការចូលរួមពិនិត្យអត្ថបទស្រាវជ្រាវ ក្នុងនាមជានិពន្ធនាយក ឬអ្នកត្រួតពិនិត្យជំនាញ នវានុវត្តន៍ក្នុងការបង្រៀនដោយប្រើប្រាស់បច្ចេកវិទ្យា ឬវិធីសាស្ត្រថ្មី ការចូលរួមអភិវឌ្ឍសកលវិទ្យាល័យ សហគមន៍ ឬសង្គម ការចូលរួមអភិវឌ្ឍវិធីសាសាស្ត្របង្រៀន ឬការទទួលស្គាល់ថាជាបុគ្គលឆ្នើមក្នុងជំនាញរបស់ខ្លួន ។ល។ (១៥ពិន្ទុ)

**ឃ. កម្រិតគុណវុឌ្ឍិ (១៥ពិន្ទុ)**

- កម្រិតសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឬថ្នាក់បណ្ឌិត (១៥ ពិន្ទុ)

តារាងនិទ្ទេសបទ និងពិន្ទុសម្រាប់ការវាយតម្លៃឋានៈសាស្ត្រាចារ្យ មានបង្ហាញលម្អិត នៅក្នុង **ឧបសម្ព័ន្ធទី១**។

## ៣. លក្ខណៈវិនិច្ឆ័យលើការវាយតម្លៃ ជ្រើសរើស និងផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ

### ៣.១. លក្ខណៈវិនិច្ឆ័យបឋមដើម្បីមានសិទ្ធិគ្រប់គ្រាន់ក្នុងការដាក់ពាក្យស្នើសុំឋានៈសាស្ត្រាចារ្យ

បេក្ខជនដែលមានបំណងដាក់ពាក្យស្នើសុំឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ ត្រូវបំពេញឱ្យបានពេញលេញនូវលក្ខណៈវិនិច្ឆ័យបឋម ដូចខាងក្រោម៖

១. មានបទពិសោធបង្រៀន និងជាគ្រូបង្រៀននៅតាមគ្រឹះស្ថានឧត្តមសិក្សា ដែលត្រូវបានតែងតាំងស៊ប់ក្នុងក្របខណ្ឌ រយៈពេលចាប់ពី ២ឆ្នាំឡើង សម្រាប់បេក្ខជនមានសញ្ញាបត្របណ្ឌិត ដែលមិនទាន់មានក្របខណ្ឌពីមុនមក

២. មានបទពិសោធបង្រៀន និងជាគ្រូបង្រៀននៅតាមគ្រឹះស្ថានឧត្តមសិក្សា ដែលត្រូវបានតែងតាំងស៊ប់ក្នុងក្របខណ្ឌ រយៈពេលចាប់ពី ៥ឆ្នាំឡើង សម្រាប់បេក្ខជនមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់

៣. មានសញ្ញាបត្រកម្រិតបណ្ឌិត និងមានស្នាដៃបោះពុម្ពសៀវភៅសិក្សា យ៉ាងតិចចំនួន ១ក្បាល សម្រាប់បេក្ខជនស្នើសុំឋានៈជាសាស្ត្រាចារ្យ។

### ៣.២. លក្ខណៈវិនិច្ឆ័យសម្រាប់កម្រិតសញ្ញាបត្រ

បេក្ខជនត្រូវមានសញ្ញាបត្រកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ឬបណ្ឌិត ស្របតាមប្រកាសលេខ ១៤៨៧ អយក.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ ស្តីពីការជ្រើសរើស និងផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ។

### ៣.៣. លក្ខណៈវិនិច្ឆ័យសម្រាប់ស្នាដៃបោះពុម្ពអត្ថបទស្រាវជ្រាវ

១. ប្រភេទអត្ថបទស្រាវជ្រាវ ដែលអាចរាប់ជាអត្ថបទស្រាវជ្រាវ ដូចមានចែងនៅក្នុងប្រកាសលេខ ១៤៨៧ អយក.ប្រក គឺជាអត្ថបទស្រាវជ្រាវដើម (Original Article) ឬវិវេចនាអត្ថបទ (Review Article) ដែលបានបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីស្រាវជ្រាវ (Academic/Scientific Journal) ឬជាជំពូកសៀវភៅ (Book Chapter) ដែលបានបោះពុម្ពផ្សាយក្នុងសៀវភៅសិក្សា។

២. អត្ថបទប្រភេទផ្សេងទៀត ដូចជាអត្ថបទស្រាវជ្រាវបោះពុម្ពផ្សាយក្នុងសន្និសីទ (Conference Paper) ឯកសារស្រាវជ្រាវមិនទាន់បានបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីស្រាវជ្រាវ (Working Paper)

អត្ថបទខ្លីបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រ (Newsletters/Bulletins) មិនអាចរាប់ជាស្នាដៃបោះពុម្ពអត្ថបទស្រាវជ្រាវទេ។

៣. ការរាប់ចំនួនអត្ថបទស្រាវជ្រាវ ត្រូវធ្វើតាមលក្ខខណ្ឌដូចខាងក្រោម៖

**លក្ខខណ្ឌទី១៖** អត្ថបទស្រាវជ្រាវដែលបានបោះពុម្ពផ្សាយក្នុងទស្សនាវដ្ដីស្រាវជ្រាវដែលស្ថិតនៅក្នុងមូលទិន្នន័យស្កូភើស (Scopus-Indexed Journals) ឬមូលទិន្នន័យស្តង់ដាអន្តរជាតិដទៃទៀត (Internationally Indexed Journals)៖

- អត្ថបទស្រាវជ្រាវដែលមានឈ្មោះបេក្ខជនជាអ្នកនិពន្ធទោល (Single Author) ចំនួន ០១អត្ថបទដែលបានបោះពុម្ព អាចរាប់ស្មើចំនួន ០១អត្ថបទ
- អត្ថបទស្រាវជ្រាវដែលមានឈ្មោះបេក្ខជនជាសហអ្នកនិពន្ធ (Co-Author) ចំនួន ០១អត្ថបទដែលបានបោះពុម្ព អាចរាប់ស្មើចំនួន ០១អត្ថបទ ប្រសិនបើបេក្ខជនជាអ្នកនិពន្ធមានឈ្មោះស្ថិតក្នុងលេខរៀងទី១ (First Author) ឬលេខរៀងបន្តបន្ទាប់រហូតដល់លេខរៀងទី៥។
- អត្ថបទស្រាវជ្រាវដែលមានឈ្មោះបេក្ខជនជាសហអ្នកនិពន្ធ (Co-Author) ចំនួន ០១អត្ថបទដែលបានបោះពុម្ព អាចរាប់ស្មើចំនួន ០,៥ (កន្លះ) អត្ថបទប៉ុណ្ណោះ ប្រសិនបើបេក្ខជនជាអ្នកនិពន្ធមានឈ្មោះស្ថិតក្នុងលេខរៀងទី៦ ឬលេខរៀងបន្តបន្ទាប់។

**លក្ខខណ្ឌទី២៖** អត្ថបទស្រាវជ្រាវដែលបានបោះពុម្ពផ្សាយក្នុងទស្សនាវដ្ដីស្រាវជ្រាវដែលមិនស្ថិតនៅក្នុងមូលទិន្នន័យស្កូភើស (Non-Scopus-Indexed Journals)៖

- អត្ថបទស្រាវជ្រាវដែលមានឈ្មោះបេក្ខជនជាអ្នកនិពន្ធទោល (Single Author) ចំនួន ០១អត្ថបទដែលបានបោះពុម្ព អាចរាប់ស្មើចំនួន ០១អត្ថបទ
- អត្ថបទស្រាវជ្រាវដែលមានឈ្មោះបេក្ខជនជាសហអ្នកនិពន្ធ (Co-Author) ចំនួន ០១អត្ថបទដែលបានបោះពុម្ព អាចរាប់ស្មើចំនួន ០១អត្ថបទ ប្រសិនបើបេក្ខជនជាអ្នកនិពន្ធមានឈ្មោះស្ថិតក្នុងលេខរៀងទី១ (First Author) ឬលេខរៀងទី២ (Second Author)
- អត្ថបទស្រាវជ្រាវដែលមានឈ្មោះបេក្ខជនជាសហអ្នកនិពន្ធ (Co-Author) ចំនួន ០១អត្ថបទដែលបានបោះពុម្ព អាចរាប់ស្មើចំនួន ០,៥ (កន្លះ) អត្ថបទប៉ុណ្ណោះ ប្រសិនបើបេក្ខជនជាអ្នកនិពន្ធមានឈ្មោះស្ថិតក្នុងលេខរៀងទី៣ ឬលេខរៀងបន្តបន្ទាប់។
- អត្ថបទស្រាវជ្រាវដែលបានបោះពុម្ពផ្សាយក្នុងទស្សនាវដ្ដីស្រាវជ្រាវដែលមិនស្ថិតនៅក្នុងមូលទិន្នន័យស្កូភើស និងត្រូវបានចាត់ទុកដោយគណៈកម្មការវាយតម្លៃផ្ដល់ឋានៈសាស្ត្រាចារ្យថាជាអត្ថបទដែលបានបោះពុម្ពផ្សាយក្នុងទស្សនាវដ្ដីស្រាវជ្រាវដែលមានគុណភាពទាបខ្លាំង (Very Low-Quality Journals) ឬទស្សនាវដ្ដីស្រាវជ្រាវក្លែងក្លាយ/បោកបញ្ឆោត (Predatory Journals) អត្ថបទស្រាវជ្រាវប្រភេទនេះ មិនត្រូវបានរាប់ជាអត្ថបទស្រាវជ្រាវទេ។ បេក្ខជនដែលមានអត្ថបទស្រាវជ្រាវប្រភេទនេះចំនួនច្រើនលើសលប់ អាចប្រឈមការបាត់បង់សិទ្ធដាក់ពាក្យស្នើសុំឋានៈសាស្ត្រាចារ្យ។

- អត្ថបទស្រាវជ្រាវដែលបានបោះពុម្ពផ្សាយក្នុងទស្សនាវដ្ដីស្រាវជ្រាវដែលមិនស្ថិតនៅក្នុងមូលទិន្នន័យស្កូភើស និងត្រូវបានរកឃើញដោយគណៈកម្មការវាយតម្លៃផ្ដល់ឋានៈសាស្ត្រាចារ្យថាជាអត្ថបទដែលត្រូវបានសរសេរដោយប្រើប្រាស់បញ្ញាសិប្បនិម្មិត (Artificial Intelligence) ច្រើនលើសលប់ អត្ថបទស្រាវជ្រាវប្រភេទនេះ មិនត្រូវបានរាប់ជាអត្ថបទស្រាវជ្រាវទេ។ បេក្ខជនដែលមានអត្ថបទស្រាវជ្រាវប្រភេទនេះចំនួនច្រើនលើសលប់ អាចប្រឈមការបាត់បង់សិទ្ធដាក់ពាក្យស្នើសុំឋានៈសាស្ត្រាចារ្យ។

## ៣.៤. លក្ខណៈវិនិច្ឆ័យសម្រាប់ស្នាដៃបោះពុម្ពសៀវភៅសិក្សា

១. សៀវភៅដែលបេក្ខជនបានសរសេរ ឬចងក្រង (ក្នុងនាមជាអ្នកនិពន្ធទោល ឬសហអ្នកនិពន្ធ) ត្រូវមានកម្រាស់យ៉ាងតិច១០០ទំព័រ (គិតគ្រប់ទំព័រទាំងអស់ ទាំងគម្របសៀវភៅ មាតិកា ខ្លឹមសារ និងឯកសារយោង ប៉ុន្តែមិនរាប់បញ្ចូលឧបសម្ព័ន្ធ) ទើបអាចរាប់ជាចំនួនសៀវភៅចំនួន ០១ក្បាល ដូចមានចែងនៅក្នុងប្រកាស។

២. សៀវភៅដែលបេក្ខជនបានសរសេរ ឬចងក្រង (ក្នុងនាមជាអ្នកនិពន្ធទោល ឬសហអ្នកនិពន្ធ) ចន្លោះពី៥០ ទៅ៩៩ទំព័រ (គិតគ្រប់ទំព័រទាំងអស់ ទាំងគម្របសៀវភៅ មាតិកា ខ្លឹមសារ និងឯកសារយោង ប៉ុន្តែមិនរាប់បញ្ចូលឧបសម្ព័ន្ធ) ត្រូវរាប់ជាចំនួន០,៥ (កន្លះ) ក្បាល។ សៀវភៅប្រភេទនេះចំនួន ០២ក្បាល ទើបអាចរាប់ជាចំនួនសៀវភៅ០១ក្បាល។

៣. សៀវភៅដែលបេក្ខជនបានសរសេរ ឬចងក្រង (ក្នុងនាមជាអ្នកនិពន្ធទោល ឬសហអ្នកនិពន្ធ) ក្រោម៥០ទំព័រ (គិតគ្រប់ទំព័រទាំងអស់ ទាំងគម្របសៀវភៅ មាតិកា ខ្លឹមសារ និងឯកសារយោង ប៉ុន្តែមិនរាប់បញ្ចូលឧបសម្ព័ន្ធ) មិនអាចរាប់ជាសៀវភៅទេ។ សៀវភៅប្រភេទនេះ អាចរាប់ស្មើចំនួន ០១អត្ថបទស្រាវជ្រាវ ប្រសិនបើមានកម្រាស់លើសពី៣០ទំព័រ (គិតគ្រប់ទំព័រទាំងអស់ ទាំងគម្របសៀវភៅ មាតិកា ខ្លឹមសារ និងឯកសារយោង ប៉ុន្តែមិនរាប់បញ្ចូលឧបសម្ព័ន្ធ) និងមានការទទួលស្គាល់ច្បាស់លាស់ ហើយការរាប់ចំនួនសៀវភៅប្រភេទនេះ ត្រូវធ្វើតាមលក្ខខណ្ឌរបស់អត្ថបទស្រាវជ្រាវ។

៤. សៀវភៅដែលបេក្ខជនបានបកប្រែពីឯកសារបរទេស (ក្នុងនាមជាអ្នកនិពន្ធទោល ឬសហអ្នកនិពន្ធ) ត្រូវមានកម្រាស់យ៉ាងតិច១០០ទំព័រ (គិតគ្រប់ទំព័រទាំងអស់ ទាំងគម្របសៀវភៅ មាតិកា ខ្លឹមសារ និងឯកសារយោង ប៉ុន្តែមិនរាប់បញ្ចូលឧបសម្ព័ន្ធ) ទើបអាចរាប់ជាស្នាដៃបោះពុម្ពសៀវភៅ ដូចមានចែងនៅក្នុងប្រកាស។។ សៀវភៅប្រភេទនេះចំនួន ០២ក្បាល ទើបអាចរាប់ជាចំនួនសៀវភៅ ០១ក្បាល។

៥. សៀវភៅដែលមានឈ្មោះបេក្ខជនជានិពន្ធនាយក (Editor) ឬសហនិពន្ធនាយក (Co-Editor) ត្រូវរាប់ដូចលក្ខខណ្ឌរបស់សៀវភៅដែលបេក្ខជនបានសរសេរ ឬចងក្រងខាងលើ

៦. ជំពូកសៀវភៅ (Book Chapter) មិនត្រូវបានរាប់ជាសៀវភៅទេ។ ជំពូកសៀវភៅត្រូវរាប់ជាអត្ថបទស្រាវជ្រាវ ហើយការរាប់ចំនួនត្រូវធ្វើតាមលក្ខខណ្ឌរបស់ស្នាដៃបោះពុម្ពអត្ថបទស្រាវជ្រាវ

៧. សៀវភៅដែលជាសៀវភៅបកប្រែ មានកម្រាស់ក្រោម១០០ទំព័រ (គិតគ្រប់ទំព័រទាំងអស់ ទាំងគម្របសៀវភៅ មាតិកា ខ្លឹមសារ និងឯកសារយោង ប៉ុន្តែមិនរាប់បញ្ចូលឧបសម្ព័ន្ធ) ឬជាសៀវភៅដែលរៀបចំជាទម្រង់ស្លាយមេរៀន (PowerPoint Slides) គឺមិនត្រូវបានរាប់ជាសៀវភៅទេ។

## ៣.៥. លក្ខណៈវិនិច្ឆ័យសម្រាប់បទពិសោធបង្រៀន ឬបទពិសោធធ្វើបទបង្ហាញជាវាគ្មិនក្នុងសន្និសីទ ឬវេទិកាសាធារណៈ

១. បេក្ខជនត្រូវមានបទពិសោធបង្រៀន ឬបទពិសោធធ្វើបទបង្ហាញក្នុងនាមជាវាគ្មិនក្នុងសន្និសីទ ឬវេទិកាសាធារណៈ ស្របតាមប្រកាសលេខ ១៤៨៧ អយក.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ ស្តីពីការជ្រើសរើស និងផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ។

២. ការចូលរួមក្នុងសន្និសីទ ឬវេទិកាសាធារណៈកម្រិតជាតិ ឬអន្តរជាតិ ក្នុងនាមជាអ្នកចូលរួមទូទៅ (Participants) ដែលមិនមែនជាអ្នកធ្វើបទបង្ហាញ ឬជាវាគ្មិន (Presenters/Speakers) មិនត្រូវបានរាប់ជាបទពិសោធធ្វើបទបង្ហាញ ឬជាវាគ្មិនក្នុងសន្និសីទ ឬវេទិកាសាធារណៈទេ។

៣. ការធ្វើបទបង្ហាញ ឬជាវាគ្មិនតែម្នាក់ឯង ឬជាក្រុមក្នុងសន្និសីទ (Conferences) វេទិកាស្រាវជ្រាវ (Research Forums) វេទិកាសាធារណៈ (Public Forums/Lecturers) សិក្ខាសាលាសាធារណៈ (Public Seminars) និងសន្និសីទផ្សេងៗ (ឧទាហរណ៍៖ Symposiums/Colloquiums) អាចរាប់ជាបទពិសោធធ្វើបទបង្ហាញ ឬជាវាគ្មិនក្នុងសន្និសីទ ឬវេទិកាសាធារណៈ ដូចមានចែងនៅក្នុងប្រកាសលេខ ១៤៨៧ អយក.ប្រក។

## ៣.៦. លក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់ស្នាដៃបង្រៀន ឬការដឹកនាំនិស្សិត

បេក្ខជនត្រូវមានការទទួលស្គាល់ស្នាដៃបង្រៀន ឬស្នាដៃដឹកនាំនិស្សិត ដែលស្របតាមលក្ខខណ្ឌខាងក្រោម៖

១. ការទទួលស្គាល់ស្នាដៃបង្រៀន សំដៅដល់ការទទួលបានពានរង្វាន់គ្រូឆ្នើម ពានរង្វាន់គ្រូបង្រៀនល្អប្រចាំឆមាស ឬឆ្នាំ លទ្ធផលវាយតម្លៃការបង្រៀនល្អពីនិស្សិត ឬគណៈគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សាសាមី លិខិតទទួលស្គាល់ការបង្រៀនចេញដោយគ្រឹះស្ថានឧត្តមសិក្សាសាមី ។ល។

២. ការដឹកនាំនិស្សិត សំដៅដល់ការដឹកនាំនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឬថ្នាក់បណ្ឌិត។ ការដឹកនាំនិស្សិតថ្នាក់បរិញ្ញាបត្រ ឬបរិញ្ញាបត្ររង មិនត្រូវបានរាប់បញ្ចូលក្នុងលក្ខណៈវិនិច្ឆ័យសម្រាប់ការដឹកនាំនិស្សិតទេ។
៣. ការដឹកនាំនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ សំដៅដល់ការដឹកនាំសរសេរនិក្ខេបបទ ឬរបាយការណ៍ស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ មិនសំដៅដល់ការដឹកនាំ ការសរសេររបាយការណ៍ស្រាវជ្រាវ ឬកិច្ចការស្រាវជ្រាវតាមមុខវិជ្ជានោះទេ។
៤. ការដឹកនាំនិស្សិតថ្នាក់បណ្ឌិត សំដៅដល់ការដឹកនាំសរសេរនិក្ខេបបទថ្នាក់បណ្ឌិត មិនសំដៅដល់ការដឹកនាំសរសេររបាយការណ៍ស្រាវជ្រាវ ឬកិច្ចការស្រាវជ្រាវតាមមុខវិជ្ជានោះទេ។ ការដឹកនាំនិស្សិតថ្នាក់បណ្ឌិតរាប់បញ្ចូលទាំងការដឹកនាំក្នុងនាមជាសាស្ត្រាចារ្យ/គ្រូដឹកនាំគោល សហសាស្ត្រាចារ្យដឹកនាំ ឬសាស្ត្រាចារ្យ/គ្រូដឹកនាំរង ប៉ុន្តែមិនរាប់បញ្ចូលដល់ការដឹកនាំ ឬការជួយនិស្សិត ក្នុងនាមជាគណៈកម្មការវាយតម្លៃនោះទេ។

## ៣.៧. លក្ខណៈវិនិច្ឆ័យសម្រាប់ស្នាដៃផ្សេងៗ

១. បេក្ខជនត្រូវមានស្នាដៃផ្សេងៗ ដែលអាចរួមមាន៖ ផលិតផលគំរូ (Prototype) ផលិតផលស្រាវជ្រាវ (Research Product) ប៉ាតង់/ប្រកាសនីយបត្រតក្កកម្ម (Patent) ការបង្កើតកម្មវិធី/សូហ្វវែរ (Applications/ Software) ការបង្កើតទ្រឹស្តី ឬម៉ូដែលក្នុងជំនាញរបស់ខ្លួន ការចូលរួមរៀបចំគោលនយោបាយ ការរៀបចំកម្មវិធីសិក្សា ការបង្កើតវីដេអូបង្រៀន ការពិសោធ ការស្រាវជ្រាវ ការចូលរួមពិនិត្យអត្ថបទស្រាវជ្រាវ ក្នុងនាមជានិពន្ធនាយក ឬអ្នកត្រួតពិនិត្យជំនាញនវានុវត្តន៍ក្នុងការបង្រៀនដោយប្រើប្រាស់បច្ចេកវិទ្យា ឬវិធីសាស្ត្រថ្មី ការចូលរួមអភិវឌ្ឍសកលវិទ្យាល័យ សហគមន៍ ឬសង្គម ការចូលរួមអភិវឌ្ឍវិធីសាសាស្ត្របង្រៀន ឬការទទួលស្គាល់ថាជាបុគ្គលឆ្នើមក្នុងជំនាញរបស់ខ្លួនជាដើម។
២. ការរាប់ចំនួនស្នាដៃផ្សេងៗ គឺធ្វើឡើងយោងទៅតាមគុណភាព គុណតម្លៃ កម្រិតស្តង់ដារ ទំហំ និងការចូលរួមចំណែកដល់ស្ថាប័ន សហគមន៍ ឬសង្គម នៃស្នាដៃនោះ។
៣. ការបញ្ជាក់ពីការទទួលស្គាល់ថាជាបុគ្គលឆ្នើមក្នុងជំនាញរបស់ខ្លួន ត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌដែលមានចែងក្នុងចំណុចទី៦.២។

## ៣.៨. លក្ខណៈវិនិច្ឆ័យសម្រាប់ក្រមសីលធម៌វិជ្ជាជីវៈ

បេក្ខជនត្រូវមានក្រមសីលធម៌វិជ្ជាជីវៈ ដោយមិនធ្លាប់មានកំហុសវិជ្ជាជីវៈ ឬមិនធ្លាប់ត្រូវបានផ្តន្ទាទោសជាប់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ស្របតាមប្រកាសលេខ ១៤៨៧ អយក.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ ស្តីពីការជ្រើសរើស និងផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ។ លក្ខណៈវិនិច្ឆ័យនេះមិនមានការដាក់ពិន្ទុទេ ប៉ុន្តែជាលក្ខខណ្ឌតម្រូវ សម្រាប់ការស្នើសុំឋានៈសាស្ត្រាចារ្យ។

### ៣.៩. លក្ខណៈវិនិច្ឆ័យសម្រាប់ការយកលក្ខខណ្ឌមួយជំនួសឱ្យលក្ខខណ្ឌមួយទៀត

ករណីបេក្ខជនបានបោះពុម្ពអត្ថបទស្រាវជ្រាវ ឬសៀវភៅសិក្សាលើសពីចំនួនដែលបានកំណត់នៅក្នុងលក្ខខណ្ឌតម្រូវ បេក្ខជនមិនអាចយកអត្ថបទស្រាវជ្រាវ ឬសៀវភៅដែលមានចំនួនលើសនោះ មករាប់បំពេញលក្ខខណ្ឌសម្រាប់ការបោះពុម្ពអត្ថបទស្រាវជ្រាវ ឬសៀវភៅសិក្សា ឬលក្ខខណ្ឌផ្សេងបានទេ។ អត្ថបទស្រាវជ្រាវ ឬសៀវភៅសិក្សាដែលមានចំនួនលើសពីលក្ខខណ្ឌតម្រូវនេះ នឹងត្រូវផ្តល់ជូនជាពិន្ទុបន្ថែម ដូចមានចែងក្នុងនិទ្ទេសបទ។

## ៤. ការបូកពិន្ទុបន្ថែមលើស្នាដៃបោះពុម្ពអត្ថបទស្រាវជ្រាវ ឬសៀវភៅសិក្សា

### ៤.១. ការលើកទឹកចិត្តដល់ការបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវ

ដើម្បីលើកទឹកចិត្តដល់ការបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវ ការបូកពិន្ទុបន្ថែមលើស្នាដៃបោះពុម្ពអត្ថបទស្រាវជ្រាវ ដែលមានចំនួនលើសពីលក្ខខណ្ឌតម្រូវ ត្រូវអនុវត្តស្របតាមលក្ខខណ្ឌខាងក្រោម៖

១. ករណីបេក្ខជនមានស្នាដៃបោះពុម្ពអត្ថបទស្រាវជ្រាវ ដែលអាចរាប់បានចំនួនចន្លោះពី៨ ទៅ ១០ អត្ថបទ បេក្ខជនទទួលបានពិន្ទុបន្ថែមចំនួន ០៥ពិន្ទុ
២. ករណីបេក្ខជនមានស្នាដៃបោះពុម្ពអត្ថបទស្រាវជ្រាវ ដែលអាចរាប់បានចំនួនចន្លោះពី១១ ទៅ ២០ អត្ថបទ បេក្ខជនទទួលបានពិន្ទុបន្ថែមចំនួន ១០ពិន្ទុ
៣. ករណីបេក្ខជនមានស្នាដៃបោះពុម្ពអត្ថបទស្រាវជ្រាវ ដែលអាចរាប់បានលើសពី២០អត្ថបទ បេក្ខជនទទួលបានពិន្ទុបន្ថែមចំនួន ១៥ពិន្ទុ។

### ៤.២. ការលើកទឹកចិត្តដល់ការបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវដែលមានគុណភាពខ្ពស់

ដើម្បីលើកទឹកចិត្តដល់ការបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវដែលមានគុណភាពខ្ពស់ និងទទួលស្គាល់ក្នុងកម្រិតអន្តរជាតិ ដូចជាអត្ថបទស្រាវជ្រាវដែលត្រូវបានបញ្ចូល ឬមានលិបិក្រមក្នុងមូលទិន្នន័យស្កូភើស (Scopus Database) ឬមូលទិន្នន័យវេបអូហ្វសាយអិន (Web of Science Database) ការបូកពិន្ទុបន្ថែមលើស្នាដៃបោះពុម្ពអត្ថបទស្រាវជ្រាវប្រភេទនេះ ត្រូវអនុវត្តស្របតាមលក្ខខណ្ឌខាងក្រោម៖

១. ករណីបេក្ខជនមានស្នាដៃបោះពុម្ពអត្ថបទស្រាវជ្រាវដែលត្រូវបានបញ្ចូល ឬមានលិបិក្រមក្នុងមូលទិន្នន័យស្កូភើស (Scopus) ឬមូលទិន្នន័យវេបអូហ្វសាយអិន (Web of Science) ចំនួនពី ៥ ទៅ១០អត្ថបទ បេក្ខជនទទួលបានពិន្ទុបន្ថែមចំនួន ៥ពិន្ទុ
២. ករណីបេក្ខជនមានស្នាដៃបោះពុម្ពអត្ថបទស្រាវជ្រាវដែលត្រូវបានបញ្ចូល ឬមានលិបិក្រមក្នុងមូលទិន្នន័យស្កូភើស (Scopus) ឬមូលទិន្នន័យវេបអូហ្វសាយអិន (Web of Science) លើសពីចំនួន ១០អត្ថបទ បេក្ខជនទទួលបានពិន្ទុបន្ថែមចំនួន ១០ពិន្ទុ។

៣. ការបូកពិន្ទុបន្ថែម សម្រាប់ស្នាដៃបោះពុម្ពអត្ថបទស្រាវជ្រាវដែលត្រូវបានបញ្ចូល ឬមានលិបិក្រមក្នុងមូលទិន្នន័យស្កូភើស (Scopus) ឬមូលទិន្នន័យវេបអូហ្វសាយអិន (Web of Science) គឺជាការបូកពិន្ទុបន្ថែមលើកទីពីរ ដើម្បីលើកទឹកចិត្តដល់ការបោះពុម្ពអត្ថបទស្រាវជ្រាវដែលមានគុណភាពខ្ពស់ និងទទួលស្គាល់ក្នុងកម្រិតអន្តរជាតិ។

## ៤.៣. ការលើកទឹកចិត្តដល់ការបោះពុម្ពផ្សាយសៀវភៅសិក្សា

ដើម្បីលើកទឹកចិត្តដល់ការបោះពុម្ពផ្សាយសៀវភៅសិក្សា ការបូកពិន្ទុបន្ថែមលើស្នាដៃបោះពុម្ពផ្សាយសៀវភៅសិក្សា ដែលមានចំនួនលើសពីលក្ខខណ្ឌតម្រូវ ត្រូវអនុវត្តស្របតាមលក្ខខណ្ឌខាងក្រោម៖

១. ករណីបេក្ខជនមានស្នាដៃបោះពុម្ពសៀវភៅសិក្សា ដែលអាចរាប់បានចំនួនចន្លោះពី៣ ទៅ ៥ ក្បាល បេក្ខជនទទួលបានពិន្ទុបន្ថែមចំនួន ០៥ពិន្ទុ

២. ករណីបេក្ខជនមានស្នាដៃបោះពុម្ពសៀវភៅសិក្សា ដែលអាចរាប់បានចំនួនចន្លោះពី៦ ទៅ១០ក្បាល បេក្ខជនទទួលបានពិន្ទុបន្ថែមចំនួន ១០ពិន្ទុ

៣. ករណីបេក្ខជនមានស្នាដៃបោះពុម្ពសៀវភៅសិក្សាចំនួនលើសពី១០ក្បាល បេក្ខជនទទួលបានពិន្ទុបន្ថែមចំនួន ១៥ពិន្ទុ

## ៤.៤. ការលើកទឹកចិត្តដល់ការបោះពុម្ពផ្សាយសៀវភៅសិក្សាដែលមានគុណភាពខ្ពស់

ដើម្បីលើកទឹកចិត្តដល់ការបោះពុម្ពផ្សាយសៀវភៅសិក្សា ដែលមានគុណភាពខ្ពស់ ទទួលស្គាល់ក្នុងកម្រិតអន្តរជាតិ ដូចជាត្រូវបានបោះពុម្ពផ្សាយដោយគ្រឹះស្ថាន ឬក្រុមហ៊ុនបោះពុម្ពផ្សាយអន្តរជាតិល្បីៗ (ឧទាហរណ៍៖ Springer, Routledge/ Taylor and Francis, John Wiley & Sons, Palgrave MacMillan, Pearson, Sage Publications, Cambridge University Press, Oxford University Press ។ល។) ការបូកពិន្ទុបន្ថែមលើស្នាដៃបោះពុម្ពសៀវភៅសិក្សាប្រភេទនេះ ត្រូវអនុវត្តស្របតាមលក្ខខណ្ឌខាងក្រោម៖

១. ករណីបេក្ខជនមានស្នាដៃបោះពុម្ពសៀវភៅសិក្សា ដែលបោះពុម្ពដោយគ្រឹះស្ថាន ឬក្រុមហ៊ុនបោះពុម្ពផ្សាយអន្តរជាតិល្បីៗ ចំនួនពី២ ទៅ៣ក្បាល បេក្ខជនទទួលបានពិន្ទុបន្ថែមចំនួន ៥ពិន្ទុ

២. ករណីបេក្ខជនមានស្នាដៃបោះពុម្ពសៀវភៅសិក្សា ដែលបោះពុម្ពដោយគ្រឹះស្ថាន ឬក្រុមហ៊ុនបោះពុម្ពផ្សាយអន្តរជាតិល្បីៗ ចំនួនលើសពី៣ក្បាល បេក្ខជនទទួលបានពិន្ទុបន្ថែមចំនួន ១០ពិន្ទុ

៣. ការបូកពិន្ទុបន្ថែម សម្រាប់ស្នាដៃបោះពុម្ពសៀវភៅសិក្សា ដែលបោះពុម្ពផ្សាយដោយគ្រឹះស្ថាន ឬក្រុមហ៊ុនបោះពុម្ពផ្សាយអន្តរជាតិល្បីៗ គឺជាការបូកបន្ថែមលើកទីពីរ ដើម្បីលើកទឹកចិត្តដល់ការបោះពុម្ពសៀវភៅសិក្សា ដែលមានគុណភាពខ្ពស់ ទទួលស្គាល់ក្នុងកម្រិតអន្តរជាតិ។

### ៤.៥. ការលើកទឹកចិត្តដល់ការបោះពុម្ពផ្សាយសៀវភៅ ឬរបាយការណ៍ស្រាវជ្រាវកម្រិតអន្តរជាតិ

ដើម្បីលើកទឹកចិត្តដល់ការបោះពុម្ពផ្សាយសៀវភៅ ឬរបាយការណ៍ស្រាវជ្រាវកម្រិតអន្តរជាតិ បោះពុម្ពផ្សាយដោយស្ថាប័នកម្រិតអន្តរជាតិល្បីៗ (ឧទាហរណ៍៖ ADB, OECD, ILO, UNESCO, UNICEF, World Bank ។ល។) ដែលមានចំនួនលើសពីលក្ខខណ្ឌតម្រូវ ការបូកពិន្ទុបន្ថែមលើស្នាដៃបោះពុម្ពសៀវភៅ ឬរបាយការណ៍ស្រាវជ្រាវប្រភេទនេះ ត្រូវអនុវត្តស្របតាមលក្ខខណ្ឌខាងក្រោម៖

១. ករណីបេក្ខជនមានស្នាដៃបោះពុម្ពសៀវភៅ ឬរបាយការណ៍ស្រាវជ្រាវកម្រិតអន្តរជាតិ ដែលអាចរាប់បានចំនួនចន្លោះពី៤ ទៅ ៥ក្បាល បេក្ខជនទទួលបានពិន្ទុបន្ថែមចំនួន ០៥ពិន្ទុ

២. ករណីបេក្ខជនមានស្នាដៃបោះពុម្ពសៀវភៅ ឬរបាយការណ៍ស្រាវជ្រាវកម្រិតអន្តរជាតិ ដែលអាចរាប់បានចំនួនលើសពី ៥ក្បាល បេក្ខជនទទួលបានពិន្ទុបន្ថែមចំនួន ១០ពិន្ទុ។

## ៥. បែបបទ និងនីតិវិធីនៃការអនុវត្តការស្នើសុំឋានៈសាស្ត្រាចារ្យ

### ៥.១. នីតិវិធីនៃការដាក់ស្នើសុំឋានៈសាស្ត្រាចារ្យ

ការដាក់ស្នើសុំឋានៈសាស្ត្រាចារ្យទាំង ៣កម្រិត ត្រូវអនុវត្តតាម ៣ដំណាក់កាល ដូចខាងក្រោម៖

- **ដំណាក់កាលទី១៖**

  គ្រឹះស្ថានឧត្តមសិក្សាត្រូវបង្កើតគណៈកម្មការវាយតម្លៃផ្តល់ឋានៈសាស្ត្រាចារ្យប្រចាំមហាវិទ្យាល័យនីមួយៗ ដែលមានសមាសភាពយ៉ាងតិច ៥រូប ដូចខាងក្រោម៖

| | |
|---|---|
| - ព្រឹទ្ធបុរសមហាវិទ្យាល័យ | ប្រធាន |
| - ព្រឹទ្ធបុរសរងមហាវិទ្យាល័យ | អនុប្រធាន |
| - ប្រធានដេប៉ាតឺម៉ង់ចំណុះមហាវិទ្យាល័យ | សមាជិក |
| - តំណាងគ្រូបង្រៀនកម្រិតឧត្តមមានសញ្ញាបត្របណ្ឌិត និងមានបទពិសោធបង្រៀន ឬស្រាវជ្រាវយ៉ាងតិច៥ឆ្នាំ | សមាជិក |
| - តំណាងអង្គភាពគ្រប់គ្រងបុគ្គលិករបស់គ្រឹះស្ថានឧត្តមសិក្សា | លេខាកត់ត្រា |

សមាសភាពជាក់ស្តែងនៃគណៈកម្មការនេះ ត្រូវកំណត់ដោយលិខិតបង្គាប់ការរបស់សាកលវិទ្យាធិការ ឬនាយកវិទ្យាស្ថាន ឬមានការទទួលស្គាល់ដោយក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានឧត្តមសិក្សាសាមី។

- **ដំណាក់កាលទី២៖**

  គណៈកម្មការវាយតម្លៃផ្តល់ឋានៈសាស្ត្រាចារ្យប្រចាំមហាវិទ្យាល័យនីមួយៗ ត្រូវបញ្ជូនលទ្ធផលនៃការវាយតម្លៃ និងឯកសារគាំទ្រផ្សេងៗ របស់បេក្ខជនម្នាក់ៗ ទៅកាន់ក្រុមប្រឹក្សាវិទ្យាសាស្ត្ររបស់គ្រឹះស្ថានឧត្តមសិក្សាសាមី ដើម្បីធ្វើការវាយតម្លៃបន្ត។ នាយកដ្ឋានជំនាញនៃក្រសួងអប់រំ យុវជន និងកីឡានឹងចូលរួមពិនិត្យ និងវាយតម្លៃជាមួយគ្រឹះស្ថានសាមី តាមការចាំបាច់។

- **ដំណាក់កាលទី៣៖**

  គ្រឹះស្ថានឧត្តមសិក្សាត្រូវបញ្ជូនលទ្ធផលនៃការវាយតម្លៃដោយគណៈកម្មការវាយតម្លៃផ្តល់ឋានៈសាស្ត្រាចារ្យប្រចាំមហាវិទ្យាល័យនីមួយៗ និងលទ្ធផលនៃការវាយតម្លៃដោយក្រុមប្រឹក្សាវិទ្យាសាស្ត្ររបស់គ្រឹះស្ថានឧត្តមសិក្សាសាមី ព្រមទាំងឯកសារគាំទ្រពាក់ព័ន្ធ មកកាន់គណៈកម្មការត្រួតពិនិត្យ និងផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ ដោយដាក់ចូលតាមច្រករដ្ឋបាលរបស់ក្រសួងអប់រំ យុវជន និងកីឡា។

## ៥.២. ការបញ្ជូនលទ្ធផលនៃការវាយតម្លៃការស្នើសុំឋានៈសាស្ត្រាចារ្យ

គ្រឹះស្ថានឧត្តមសិក្សា ត្រូវបញ្ជូនលទ្ធផលនៃការវាយតម្លៃការស្នើសុំឋានៈសាស្ត្រាចារ្យដោយគណៈកម្មការវាយតម្លៃផ្តល់ឋានៈសាស្ត្រាចារ្យប្រចាំមហាវិទ្យាល័យនីមួយៗ និងលទ្ធផលនៃការវាយតម្លៃដោយក្រុមប្រឹក្សាវិទ្យាសាស្ត្ររបស់គ្រឹះស្ថានឧត្តមសិក្សាសាមី ព្រមទាំងឯកសារគាំទ្រពាក់ព័ន្ធ មកក្រសួងអប់រំ យុវជន និងកីឡា។ ឯកសារដែលត្រូវបញ្ជូនមកក្រសួងអប់រំ យុវជន និងកីឡា រួមមាន៖

១. លិខិតស្នើសុំវាយតម្លៃ និងផ្តល់ឋានៈសាស្ត្រាចារ្យ របស់គ្រឹះស្ថាន
២. តារាងបញ្ជីឈ្មោះបេក្ខជនស្នើសុំឋានៈសាស្ត្រាចារ្យតាមកម្រិត ដោយបញ្ជាក់ពីឈ្មោះ ភេទ តួនាទី សញ្ញាបត្រ (បរិញ្ញាបត្រជាន់ខ្ពស់ ឬបណ្ឌិត) មហាវិទ្យាល័យ និងជំនាញ
៣. របាយការណ៍ស្វ័យវាយតម្លៃកម្រិតគ្រឹះស្ថាន
៤. របាយការណ៍ស្វ័យវាយតម្លៃកម្រិតមហាវិទ្យាល័យ
៥. ឯកសារគាំទ្រ ឬភ័ស្តុតាងផ្សេងៗសម្រាប់បេក្ខជនម្នាក់ៗ

## ៥.៣. ការរៀបចំឯកសារគាំទ្រការស្នើសុំឋានៈសាស្ត្រាចារ្យ

ឯកសារគាំទ្រ ឬភ័ស្តុតាងផ្សេងៗសម្រាប់បេក្ខជនម្នាក់ៗ ដែលមានបំណងស្នើសុំឋានៈសាស្ត្រាចារ្យតាមកម្រិតនីមួយៗ ត្រូវស្កេនជាឯកសារ PDF ដាក់បញ្ចូលក្នុង Folder (ពីលេខ០ ដល់ លេខ៧) តាមប្រភេទនៃឯកសារ និងតាមលំដាប់លំដោយនៃលក្ខណៈវិនិច្ឆ័យនីមួយៗ ដូចខាងក្រោម៖

០. ពាក្យស្នើសុំឋានៈសាស្ត្រាចារ្យ (រួមមាន៖ ពាក្យស្នើសុំឋានៈសាស្ត្រាចារ្យ ជីវប្រវត្តិសង្ខេប លិខិតបញ្ជាក់ពីការបំពេញលក្ខណៈវិនិច្ឆ័យបឋម និងលិខិតបញ្ជាក់ពីការបំពេញគ្រប់ពិន្ទុ ដើម្បីទទួលបានឋានៈសាស្ត្រាចារ្យដែលបានស្នើសុំ)
១. កម្រិតសញ្ញាបត្រ
២. ស្នាដៃបោះពុម្ពអត្ថបទស្រាវជ្រាវ
៣. ស្នាដៃបោះពុម្ពសៀវភៅសិក្សា
៤. បទពិសោធបង្រៀន ឬបទពិសោធជាវាគ្មិនក្នុងសន្និសីទ/វេទិកាសាធារណៈ
៥. ការទទួលស្គាល់ស្នាដៃបង្រៀន ឬការដឹកនាំនិស្សិត
៦. ស្នាដៃផ្សេងៗ

៧. ក្រមសីលធម៌វិជ្ជាជីវៈ

ឯកសារគាំទ្រ ឬភ័ស្តុតាងផ្សេងៗ ដែលត្រូវស្កែនជាឯកសារ PDF និងបានដាក់បញ្ចូលក្នុង Folder តាមប្រភេទនៃឯកសារ និងតាមលំដាប់លំដោយនៃលក្ខណៈវិនិច្ឆ័យនីមួយៗ ត្រូវអនុវត្តស្របតាមលក្ខខណ្ឌខាងក្រោម៖

១. បេក្ខជនម្នាក់ៗ ត្រូវមាន Folder របស់ខ្លួនមួយ ដែលក្នុង Folder នោះ មាន Folder ផ្សេងទៀត ចំនួន ៨ (ប្រាំបី) រៀបចំតាមលំដាប់លំដោយនៃលក្ខណៈវិនិច្ឆ័យនីមួយៗ ដូចមានចែងខាងលើ
២. Folder ទាំងអស់ត្រូវជា Folder ធម្មតាដែលអាចចុចបើកមើលបាន តាមតំណដែលបានផ្តល់ដោយគ្រឹះស្ថាន មិនមែនជាប្រភេទឯកសារ ZIP (ZIP files ឬ ZIP folders) នោះទេ
៣. ឯកសារសម្រាប់បេក្ខជនម្នាក់ៗ ដែលបានដាក់បញ្ចូលក្នុង Folder តាមប្រភេទនៃឯកសារ និងតាមលំដាប់លំដោយនៃលក្ខណៈវិនិច្ឆ័យនីមួយៗ ត្រូវបញ្ជូនចូលក្នុង Google Drive
៤. បន្ទាប់ពីបានបញ្ជូនឯកសារគាំទ្រពាក់ព័ន្ធការស្នើសុំឋានៈសាស្ត្រាចារ្យ មកកាន់គណៈកម្មការត្រួតពិនិត្យ និងផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ គ្រឹះស្ថានឧត្តមសិក្សានីមួយ ត្រូវផ្ញើតំណរួម (Google Drive Link សម្រាប់គ្រឹះស្ថាន) ដែលមានឯកសារផ្សេងៗរៀបចំតាម Folder របស់បេក្ខជនម្នាក់ៗ មកនាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ ឱ្យបានយ៉ាងយូរបំផុត ២ ថ្ងៃ បន្ទាប់ពីមានបញ្ជូនឯកសារស្នើសុំឋានៈសាស្ត្រាចារ្យ មកកាន់ក្រសួងអប់រំ យុវជន និងកីឡា។

### ៥.៤. ការដាក់ស្នើសុំឋានៈសាស្ត្រាចារ្យសាជាថ្មី

គ្រឹះស្ថានឧត្តមសិក្សា អាចស្នើសុំវាយតម្លៃ និងផ្តល់ឋានៈសាស្ត្រាចារ្យ ចំនួន ១ (មួយ) ដង ក្នុងមួយឆ្នាំសិក្សា។ មុនដាក់ពាក្យស្នើសុំការផ្តល់ឋានៈសាស្ត្រាចារ្យ បេក្ខជនទាំងអស់ត្រូវពិនិត្យលក្ខណៈវិនិច្ឆ័យសម្រាប់កម្រិតនៃឋានៈសាស្ត្រាចារ្យនីមួយៗ ឱ្យបានច្បាស់លាស់ ជៀសវាងការការដាក់ពាក្យស្នើសុំ ដែលមិនអាចបំពេញឱ្យបានពេញលេញនូវលក្ខណៈវិនិច្ឆ័យបឋម និងលក្ខណៈវិនិច្ឆ័យផ្សេងៗ តាមកម្រិតនៃឋានៈសាស្ត្រាចារ្យ នីមួយៗ។

## ៦. ឯកសារដែលបេក្ខជនត្រូវរៀបចំ ដើម្បីស្នើសុំឋានៈសាស្ត្រាចារ្យ

### ៦.១. ឯកសារដែលបេក្ខជនត្រូវរៀបចំ ដើម្បីស្នើសុំឋានៈសាស្ត្រាចារ្យ

បេក្ខជនដែលស្នើសុំឋានៈសាស្ត្រាចារ្យទាំង ៣កម្រិត ត្រូវរៀបចំឯកសារ ដូចខាងក្រោម៖

១. ពាក្យស្នើសុំឋានៈសាស្ត្រាចារ្យ
២. ជីវប្រវត្តិសង្ខេប (Academic CV)
៣. លិខិតបញ្ជាក់ពីការបំពេញលក្ខណៈវិនិច្ឆ័យបឋម
៤. លិខិតបញ្ជាក់ពីការបំពេញគ្រប់ពិន្ទុ ដើម្បីទទួលបានឋានៈសាស្ត្រាចារ្យដែលបានស្នើសុំ

៥. ឯកសារគាំទ្រ ឬភស្តុតាងផ្សេងៗតាមប្រភេទនៃឯកសារ និងតាមលំដាប់លំដោយនៃលក្ខណៈវិនិច្ឆ័យនីមួយៗ

គំរូនៃឯកសារទាំង៥នេះ មានបង្ហាញនៅក្នុង**ឧបសម្ព័ន្ធទី២ ដល់ឧបសម្ព័ន្ធទី៦**។

## ៦.២. ឯកសារគាំទ្រសម្រាប់ការស្នើសុំឋានៈសាស្ត្រាចារ្យ

បេក្ខជនដែលមានបំណងដាក់ពាក្យស្នើសុំឋានៈសាស្ត្រាចារ្យ ទាំងឋានៈជាសាស្ត្រាចារ្យ សាស្ត្រាចារ្យរង ឬសាស្ត្រាចារ្យជំនួយ ត្រូវរៀបចំឯកសារគាំទ្រ ដើម្បីបំពេញលក្ខខណ្ឌតម្រូវនៃកម្រិតឋានៈសាស្ត្រាចារ្យដែលបានស្នើសុំ ដូចខាងក្រោម៖

### ១. ពាក្យស្នើសុំឋានៈសាស្ត្រាចារ្យ

- ត្រូវផ្តល់ពាក្យស្នើសុំឋានៈសាស្ត្រាចារ្យ ដែលមានហត្ថលេខាសាមី ហត្ថលេខាប្រធានគណៈកម្មការវាយតម្លៃផ្តល់ឋានៈសាស្ត្រាចារ្យប្រចាំមហាវិទ្យាល័យ និងហត្ថលេខាប្រធានក្រុមប្រឹក្សាវិទ្យាសាស្ត្ររបស់គ្រឹះស្ថានឧត្តមសិក្សាសាមី
- ត្រូវផ្តល់ជីវប្រវត្តិសង្ខេប (Academic CV) ដែលមានរៀបរាប់ព័ត៌មានផ្ទាល់ខ្លួន និងព័ត៌មានផ្សេងៗពាក់ព័ន្ធលក្ខណៈវិនិច្ឆ័យសម្រាប់ឋានៈសាស្ត្រាចារ្យ
- ត្រូវផ្តល់លិខិតបញ្ជាក់ពីការបំពេញលក្ខណៈវិនិច្ឆ័យបឋម ដែលមានហត្ថលេខាសាមី និងហត្ថលេខាប្រធានគណៈកម្មការវាយតម្លៃផ្តល់ឋានៈសាស្ត្រាចារ្យប្រចាំមហាវិទ្យាល័យ
- លិខិតបញ្ជាក់ពីការបំពេញគ្រប់ពិន្ទុ ដើម្បីទទួលបានឋានៈសាស្ត្រាចារ្យដែលបានស្នើសុំ ដែលមានហត្ថលេខាសាមី ហត្ថលេខាប្រធានគណៈកម្មការវាយតម្លៃផ្តល់ឋានៈសាស្ត្រាចារ្យប្រចាំមហាវិទ្យាល័យ និងហត្ថលេខាប្រធានក្រុមប្រឹក្សាវិទ្យាសាស្ត្ររបស់គ្រឹះស្ថានឧត្តមសិក្សាសាមី

### ២. កម្រិតសញ្ញាបត្រ

- ត្រូវផ្តល់សញ្ញាបត្របណ្ឌិត ឬបរិញ្ញាបត្រជាន់ខ្ពស់ ដែលបានបញ្ជាក់ដោយសាលារាជធានី/ខេត្ត សម្រាប់បេក្ខជនដែលបានបញ្ចប់ការសិក្សាក្នុងប្រទេស
- ត្រូវផ្តល់សញ្ញាបត្របណ្ឌិត ឬបរិញ្ញាបត្រជាន់ខ្ពស់ ដែលបានធ្វើសមមូលដោយក្រសួងអប់រំ យុវជន និងកីឡា សម្រាប់បេក្ខជនដែលបានបញ្ចប់ការសិក្សាពីបរទេស
- ត្រូវផ្តល់សញ្ញាបត្រដែលបានបញ្ជាក់ ឬបានធ្វើសមមូលរួច ជាឯកសារ PDF ឬរូបភាព។

### ៣. ស្នាដៃបោះពុម្ពអត្ថបទស្រាវជ្រាវ

- ចំពោះស្នាដៃបោះពុម្ពអត្ថបទស្រាវជ្រាវ ត្រូវផ្តល់ឯកសារដែលបញ្ជាក់ពីការបោះពុម្ពអត្ថបទស្រាវជ្រាវ ដែលត្រូវមានឈ្មោះអ្នកនិពន្ធ ឆ្នាំនៃការបោះពុម្ពផ្សាយ ចំណងជើងអត្ថបទស្រាវជ្រាវ ឈ្មោះទស្សនាវដ្តីស្រាវជ្រាវ លេខនៃឆ្នាំដែលបានបោះពុម្ពផ្សាយ (Volume Number) និងលេខដែលបានបោះពុម្ពផ្សាយ (Issue Number) ប្រសិនបើមាន។

- ត្រូវផ្តល់ DOI ឬ តំណភ្ជាប់ (Link) របស់អត្ថបទស្រាវជ្រាវដែលបានបោះពុម្ពផ្សាយនោះ ប្រសិនបើមាន។
- ត្រូវផ្តល់ឯកសារទាំងអស់ ជាឯកសារ PDF។

## ៤. ស្នាដៃបោះពុម្ពសៀវភៅសិក្សា

- ចំពោះស្នាដៃបោះពុម្ពសៀវភៅសិក្សា ត្រូវផ្តល់ឯកសារ ឬលិខិតបញ្ជាក់ពីការទទួលស្គាល់សៀវភៅសិក្សាដែលបានបោះពុម្ព ពីកម្រិតគ្រឹះស្ថាន (មានហត្ថលេខា ឬត្រារបស់សាកលវិទ្យាធិការ ឬនាយកវិទ្យាស្ថាន) ឬការទទួលស្គាល់កម្រិតជាតិពីបណ្ណាល័យជាតិ ឬគ្រឹះស្ថាន បោះពុម្ពផ្សាយ ឬនាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឬការទទួលស្គាល់កម្រិតអន្តរជាតិ ដែលមានលេខ ISBN ឬ DOI ឬ តំណភ្ជាប់ (Link) ជាភ័ស្តុតាង។
- ឯកសារសៀវភៅសិក្សាដែលត្រូវផ្តល់ យ៉ាងហោចណាស់ត្រូវមានគម្របសៀវភៅ ទំព័ររក្សាសិទ្ធិអ្នកនិពន្ធ (Copyrights Page) ឬផ្នែកដែលបង្ហាញឈ្មោះអ្នកនិពន្ធ តារាងមាតិកាទាំងស្រុង (Table of Contents) និងគំរូជំពូកនៃសៀវភៅយ៉ាងហោចណាស់មួយជំពូក។ បេក្ខជនក៏អាចបញ្ជូនឯកសារសៀវភៅសិក្សាទាំងស្រុង ដើម្បីផ្តល់ភាពងាយស្រួលដល់ការពិនិត្យ និងវាយតម្លៃ
- ត្រូវផ្តល់ឯកសារទាំងអស់ ជាឯកសារ PDF។

## ៥. បទពិសោធបង្រៀន ឬបទពិសោធធ្វើបទបង្ហាញជាវាគ្មិនក្នុងសន្និសីទ ឬវេទិកាសាធារណៈ

- ចំពោះបទពិសោធបង្រៀន ត្រូវផ្តល់ឯកសារ ឬលិខិតបញ្ជាក់ពីចំនួនឆ្នាំនៃបទពិសោធបង្រៀន ដែលចេញដោយក្រុមប្រឹក្សាវិទ្យាសាស្ត្ររបស់គ្រឹះស្ថានសាមី និងលិខិតបញ្ជាក់ពីការតែងតាំងស៊ប់ក្នុងក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- ចំពោះបទពិសោធជាវាគ្មិនក្នុងសន្និសីទ ឬវេទិកាសាធារណៈ ត្រូវផ្តល់ឯកសារដែលបញ្ជាក់ពីការធ្លាប់ធ្វើបទបង្ហាញ ឬជាវាគ្មិនក្នុងសន្និសីទ ឬវេទិកាសាធារណៈ កម្រិតជាតិ ឬអន្តរជាតិ ឱ្យបានពេញលេញ។ ឯកសារបញ្ជាក់អាចជា លិខិតបញ្ជាក់ពីការធ្វើបទបង្ហាញ លិខិតថ្លែងអំណរគុណពីការធ្វើបទបង្ហាញ/ជាវាគ្មិន ឬអ៊ីម៉ែលថ្លែងអំណាគុណពីការធ្វើបទបង្ហាញ។
- ត្រូវផ្តល់ឯកសារទាំងអស់ ជាឯកសារ PDF។

## ៦. ស្នាដៃបង្រៀន ឬការដឹកនាំនិស្សិត

- ចំពោះស្នាដៃបង្រៀន ត្រូវផ្តល់ឯកសារ ឬលិខិតបញ្ជាក់ពីការទទួលស្គាល់ស្នាដៃបង្រៀន ដូចជា លិខិតបញ្ជាក់ពីការទទួលបានពានរង្វាន់គ្រូឆ្នើម ពានរង្វាន់គ្រូបង្រៀនល្អប្រចាំឆមាស/ឆ្នាំ លទ្ធផលវាយតម្លៃការបង្រៀនល្អពីនិស្សិត ឬគណៈគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សាសាមី លិខិតទទួលស្គាល់ការបង្រៀនចេញដោយគ្រឹះស្ថានឧត្តមសិក្សាសាមី ។ល។

- ចំពោះការដឹកនាំនិស្សិត ត្រូវផ្ដល់ឯកសារ ឬលិខិតបញ្ជាក់ពីការដឹកនាំនិស្សិត ក្នុងនាមជាសាស្ត្រាចារ្យ/គ្រូដឹកនាំគោល ឬរង។ ឯកសារដែលអាចបញ្ជាក់បានរួមមាន៖ លិខិតឧទ្ទេសនាម និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឬថ្នាក់បណ្ឌិតរបស់និស្សិត របាយការណ៍ស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ (មានឈ្មោះបេក្ខជនជាសាស្ត្រាចារ្យ/គ្រូដឹកនាំគោល ឬរង) ឬឯកសារដឹកនាំនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឬថ្នាក់បណ្ឌិតសរសេរអត្ថបទស្រាវជ្រាវ (មានអត្ថបទស្រាវជ្រាវជាភស្តុតាង)
- ត្រូវផ្ដល់ឯកសារទាំងអស់ ជាឯកសារ PDF។

## ៧. ស្នាដៃផ្សេងៗ

- ត្រូវផ្ដល់ឯកសារ ឬលិខិតបញ្ជាក់ពីស្នាដៃផ្សេងៗ ដែលអាចមានដូចខាងក្រោម៖
